កាកបាទក្រហមកម្ពុជា
CAMBODIAN RED CROSS

# គោលនយោបាយការពារកុមារ

## មិថុនា ២០១៤


កាកបាទក្រហមកម្ពុជា ឡូត៍ ១៦A ផ្លូវ ៦៥៤ កែង ២៧១ អូរបែកក្អម សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (855-23) 881 511, ទូរសារ: (855-23) 881 522, P.O.Box:69
វេបសាយ : www.redcross.org.k, អ៊ីម៉ែល: info@redcross.org.kh, crc_adm@online.com.kh


---


បោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស ចំនួន ១២៥០ ច្បាប់ ឧបត្ថម្ភដោយ ៖
ខែ កញ្ញា ឆ្នាំ ២០១៤

Australian Red Cross
THE POWER OF HUMANITY

# មាតិកា

ទំព័រ


១. សេចក្តីប្រកាសគោលនយោបាយ ........................................ ១

២. កម្មវត្ថុ ........................................ ១

៣. វិសាលភាព ........................................ ២

៤. គោលការណ៍ណែនាំ ........................................ ២

៥. និយមន័យ ........................................ ៣

៦. គោលការណ៍ណែនាំប្រតិបត្តិ ........................................ ៦

៧. ការតាមដាន និងពិនិត្យឡើងវិញ ........................................ ១១

ឧបសម្ព័ន្ធ

# គោលនយោបាយការពារកុមារ

## ១. សេចក្តីប្រកាសគោលនយោបាយ

កាកបាទក្រហមកម្ពុជា បានទទួលស្គាល់ថា កុមារជាជនរងគ្រោះមួយក្នុងចំណោមជនរងគ្រោះជាច្រើនក្នុងសង្គម។ កាកបាទក្រហមកម្ពុជាក៏ទទួលស្គាល់ផងដែរថា ការធ្វើការងារជាមួយកុមារ គឺជាទំនួលខុសត្រូវមួយដ៏សំខាន់ជាទីបំផុត ហើយគ្រប់ពេលវេលាទាំងអស់ កុមារមានសិទ្ធិក្នុងការទទួលបានសុវត្ថិភាព និងការការពារ។ តាមរយៈការអនុវត្តគោលនយោបាយនេះ កាកបាទក្រហមកម្ពុជា មានគោលបំណងសំដៅបង្កើនអោយមាននូវបរិយាកាសមួយដែល ប្រកបដោយសុវត្ថិភាពដល់កុមារដែលកាកបាទក្រហមកម្ពុជា កំពុងធ្វើការងារជាមួយ។

កាកបាទក្រហមកម្ពុជា មានកាតព្វកិច្ចថែទាំកុមារដែលខ្លួនកំពុងធ្វើការជាមួយ និងទទួលខុសត្រូវរក្សាសុវត្ថិភាពរបស់ពួកគេ។ កាកបាទក្រហមកម្ពុជា មានកាតព្វកិច្ចគោរពតាមច្បាប់ស្តីពីបទឧក្រិដ្ឋក្នុងស្រុក អន្តរជាតិ និងអនុសញ្ញាអន្តរជាតិទាំងឡាយ ស្តីពីសិទ្ធិការពារកុមារ។

កាកបាទក្រហមកម្ពុជា នឹងការពារកុមារទាំងឡាយដោយមិនគិតពីសញ្ជាតិ ប្រពៃណី វប្បធម៌ យេនឌ័រ សាសនា និន្នាការនយោបាយ ស្ថានភាពសេដ្ឋកិច្ចសង្គម ក្រុមគ្រួសារ ប្រវត្តិប្រព្រឹត្តបទឧក្រិដ្ឋ សុខភាពរាងកាយ ឬផ្លូវចិត្ត។

## ២. គម្មវត្ថុ

គោលនយោបាយការពារកុមារ មានគោលបំណងការពារកុមារអាយុក្រោម១៨ឆ្នាំ អោយរួចផុតពីការរំលោភ ការប្រមាទ និងការធ្វើអាជីវកម្មក្នុងបរិបទនៃកម្មវិធី និងប្រតិបត្តិការរបស់កាកបាទក្រហមកម្ពុជា។ គោលនយោបាយទាំងនេះនឹងសម្រេចទៅបានតាមរយៈ ៖

- ការរកឃើញ និងគ្រប់គ្រងហានិភ័យដែលជាប់ទាក់ទង ក្នុងការងារជាមួយកុមារ។
- ធ្វើអោយប្រាកដថាមន្ត្រី អ្នកស្ម័គ្រចិត្ត និងសមាជិក-សមាជិការ ដឹងអំពីការទទួលខុសត្រូវរបស់ខ្លួនក្នុងការការពារកុមារ។
- ធ្វើអោយប្រាកដថានីតិវិធីទាំងឡាយ ត្រូវមាននៅនឹងកន្លែងរង់ចាំការអនុវត្ត ហើយមន្ត្រីទាំងអស់យល់ដឹងអំពីការប្រើប្រាស់នីតិវិធី ទាំងអស់នេះ ដើម្បីដោះស្រាយជំលោះដែលទាក់ទងដល់ការការពារកុមារ។

## ៣. វិសាលភាព

គោលនយោបាយការពារកុមារនេះ បង្កើតឡើងសម្រាប់ មន្ត្រី អ្នកស្ម័គ្រចិត្ត សមាជិក-សមាជិកា និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់ ដែលបំរើការងារក្នុងកាកបាទក្រហមកម្ពុជា។

## ៤. គោលការណ៍ណែនាំ

គោលនយោបាយនេះបង្ហាញឱ្យដឹងអំពីគោលការណ៍ និងសេចក្តីត្រូវការដូចខាងក្រោម៖

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ គឺជាមូលដ្ឋានទូទៅសម្រាប់ការការពារកុមារ ដែលបញ្ជាក់ថាកុមារមានសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេមិនអាចបំបែកបាន។
- យុទ្ធសាស្ត្រសហព័ន្ធអន្តរជាតិកាកបាទក្រហម អឌ្ឍចន្ទក្រហមស្តីពីការការពារ អំពើហិង្សា ការទប់ស្កាត់ និងការឆ្លើយតប ក្នុងផ្នែកការការពារអំពើហិង្សា ទទួលស្គាល់ថា យុវជននិងកុមារទទួលរងផលប៉ះពាល់ដោយវិសមាមាត្រនៃ អំពើហិង្សា ការរើសអើង និង

ការបដិសេធ។ ដូច្នេះកុមារទាមទារអោយមានការយកចិត្តទុកដាក់និងសកម្មភាពអំពីយើងជាពិសេស។

- ការសន្យាលេខ ១០១ របស់សហព័ន្ធអន្តរជាតិកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម ស្តីពីការការពារកុមារ តាមរយៈការគាំទ្រពីសមាគមជាតិ ក្នុងការប្រកាន់យក និងការអនុវត្តវិធីសាស្ត្រគ្មានការលើកលែងចំពោះការធ្វើអាជីវកម្មផ្លូវភេទ និងការរំលោភផ្លូវភេទលើកុមារ តាមរយៈការជួយកុមារដើម្បីលើកកម្ពស់បរិយាកាសសុវត្ថិភាពសម្រាប់កុមារក្នុងកន្លែងធ្វើការ និងក្នុងកម្មវិធីទាំងឡាយ។ លើសពីនេះទៅទៀត សមាគមជាតិត្រូវធានាការលើកកម្ពស់ការយល់ដឹងអំពីការរំលោភបំពានអំណាច។

## ៥. និយមន័យ

- " **មនុស្សពេញវ័យ** " គឺជាមនុស្សដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។
- " **ការរំលោភបំពានលើកុមារ** " មានអត្ថន័យមួយ ឬច្រើន ដូចខាងក្រោម ៖
  - ការរំលោភបំពានលើរាងកាយ
  - ការរំលោភបំពានផ្លូវភេទ
  - ការរំលោភផ្លូវចិត្ត
  - ការមិនយកចិត្តទុកដាក់
  - ការកេងប្រវ័ញ្ច
- " **កុមារ** " គឺជាមនុស្សដែលមានអាយុមិនលើសពី១៨ឆ្នាំ។

- " **រូបអាសអាភាសន៍របស់កុមារ** " គឺសំដៅលើរូបភាពក្នុងភាពយន្ត (ដូចគ្នាទៅនឹងរូបភាពរំលោភបំពានលើកុមារ) រួមទាំងការសរសេរពិពណ៌នាលំអិតពីសកម្មភាពផ្លូវភេទជាមួយកុមារ។
- " **ការការពារកុមារ** " សកម្មភាព ឬគំនិតផ្តួចផ្តើមយកចិត្តទុកដាក់លើការបង្ការ និងការឆ្លើយតប ទៅនឹងឧប្បត្តិហេតុជាក់ស្តែងទាំងឡាយនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ។
- " **ការការពារសុវត្ថិភាពកុមារ** " និយាយអំពីវិធានការណ៍ ដែលបង្កើតឡើងនិងអនុវត្តន៍ដោយអង្គភាព សំដៅធានាសុវត្ថិភាព សុខុមាលភាព និងការការពារកុមារ ខណៈពេលដែលកុមារកំពុងបំពេញតួនាទីរបស់ខ្លួន។
- " **ការរៀបចំសុវត្ថិភាពកុមារ** " ការរៀបចំសុវត្ថិភាពកុមារ គឺជាការប្តេជ្ញាចិត្តក្នុងការការពារកុមារ អោយរួចផុតពីការប្រមាថ ផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត សតិអារម្មណ៍ និង ការមិនយកចិត្តទុកដាក់។ ទាំងនេះគឺជាការប្តេជ្ញាចិត្ត ដែលបង្កប់ក្នុងវប្បធម៌របស់អង្គការ ដែលឆ្លុះបញ្ចាំងក្នុងគោលនយោបាយ និងនិតិវិធីរបស់អង្គការ ដែលត្រូវបានគេយល់ដឹងនិងអនុវត្តក្នុងអង្គភាពគ្រប់ស្រទាប់។
- "**ការរំលោភផ្លូវចិត្ត**"មានលំនាំជាបែបបទនៃការប្រព្រឹត្តដោយផ្ទាល់ និងពុំរៃទៅលើកុមារ និងមនុស្សវ័យក្មេង ដែលតាមរយៈនេះ ភាពមានជំនឿទុកចិត្តលើខ្លួនឯង និងសមត្ថភាពសង្គមរបស់កុមារ ត្រូវបានបំផ្លាញជាបណ្តើរៗ។

- " **ការកេងប្រវ័ញ្ច** " ការកេងយកផលប្រយោជន៍ពីភាពងាយរងគ្រោះរបស់កុមារតាមរយៈកំលាំងពលកម្មដោយបង្ខំ ការជួញដូរផ្លូវភេទ រូបភាពអាសអាភាសន៍ ឬសកម្មភាព និងគ្រោះថ្នាក់ដទៃទៀត។
- " **ការសំអិតសំអាងដើម្បីពង្វក់ចិត្ត** " សកម្មភាពធ្វើអោយកុមារ មានជំនឿទុកចិត្តមកលើខ្លួន និងធ្វើអោយកុមារចាត់ទុកខ្លួនថាជាអ្នកថែរក្សាពួកគេ ដើម្បីគោលបំណងចុងក្រោយ គឺការរំលោភផ្លូវភេទ។
- " **ការមិនយកចិត្តទុកដាក់** " សំដៅការខកខានក្នុងការផ្តល់អោយកុមារ ឬមនុស្សវ័យក្មេងនូវតំរូវការជាមូលដ្ឋាន ក្នុងរូបភាពជាសកម្មភាពដោយផ្ទាល់ ឬដោយមានចេតនា ឬក្នុងរូបភាពជាភាពគ្មានសកម្មភាពដោយចេតនាក្នុងការថែទាំកុមារ ឬមនុស្សវ័យក្មេង។
- " **ការរំលោភផ្លូវកាយ** " គឺការប្រព្រឹត្តមានលក្ខណៈទូទៅដូចជា ការដាល់ ទះ តប់ វាយ ធាក់ ចាក់ ដុត មួល ឬទង្វើទាំងឡាយណាដែលធ្វើឱ្យគ្រោះថ្នាក់ដល់កុមារ ឬជួនកាលលើមនុស្សវ័យក្មេង ប៉ុន្តែមិនមែនជានិច្ចជាកាលធ្វើឱ្យមានស្នាមរបួសនោះទេ។
- "**ការរំលោភផ្លូវភេទ**" ជាសភាវៈនៅពេលដែលអ្នកណាម្នាក់ដែលមានអំណាចក្នុងតួនាទីរបស់ខ្លួនលើកុមារ ឬមនុស្សវ័យក្មេង ប្រើអំណាចនោះដើម្បីការសប្បាយផ្លូវភេទ ឬបំពេញចំណង់ ឬចំណេញលើសេដ្ឋកិច្ចរបស់គាត់ ឬនាង។ អ្នកដែលប្រើអំណាច ក្នុងតួនាទីនោះអាចជាមនុស្សចាស់ មនុស្សវ័យក្មេង តែចាស់ជាងកុមាររងគ្រោះ និងមនុស្សពេញវ័យ។

- “ **ការធ្វើការជាមួយកុមារ** ” ការធ្វើការក្នុងមុខងារដែលមានការប្រាស្រ័យទាក់ទងជាប្រចាំជាមួយកុមារ ទាំងតាមរយៈមុខងារ ឬតួនាទី ក្នុងភារៈកិច្ចការងារ ឬបរិយាកាសការងារជាក់ស្តែង។
- “ **មនុស្សវ័យក្មេង** ” គឺកុមារដែលមាអាយុចន្លោះពី ១២ ឆ្នាំ ទៅ ១៨ ឆ្នាំ។

## ៦. គោលការណ៍ណែនាំប្រតិបត្តិ

### ៦.១. ក្រមសីលធម៌-វិន័យរបស់មន្ត្រីកាកបាទក្រហមកម្ពុជា និង ក្រមប្រតិបត្តិស្តីពីគោលនយោបាយការពារកុមារ

កាកបាទក្រហមកម្ពុជា ផ្តល់ការណែនាំ អំពីវិធីកាត់បន្ថយ ហានិភ័យចំពោះកុមារបទដ្ឋានការប្រព្រឹត្ត និងអនុវត្តន៍ដែលតម្រូវអោយមានក្នុងគ្រប់ពេលវេលាទាំងអស់ ពេលធ្វើការទាក់ទងជាមួយកុមារ។

**ក.** មន្ត្រី អ្នកស្ម័គ្រចិត្ត និងយុវជនកាកបាទក្រហមកម្ពុជា ទាំងអស់ នឹងត្រូវចុះហត្ថលេខាលើក្រមសីលធម៌-វិន័យ របស់កាកបាទក្រហមកម្ពុជា និងក្រមប្រតិបត្តិស្តីពីគោលនយោបាយគាំពារកុមារ។

ខ. ចំពោះមន្ត្រីទាំងឡាយ ដែលមិនគោរពតាមក្រមសីលធម៌-វិន័យ និងក្រមប្រតិបត្តិ ត្រូវប្រឈមមុខចំពោះនីតិវិធីក្រុមប្រឹក្សាវិន័យ ដូចជាការផ្លាស់ប្តូរភារកិច្ច ការបញ្ចប់ការងារ ឬសកម្មភាពផ្លូវច្បាប់ យោងតាម ល័ក្ខខ័ណ្ឌការងារកាកបាទក្រហមកម្ពុជា។

### ៦.២ ការជ្រើសរើសមន្ត្រី

កាកបាទក្រហមកម្ពុជា គឺជាអង្គការដែលមានសុវត្ថិភាពសម្រាប់កុមារ ហើយកាកបាទក្រហមកម្ពុជា នឹងជំរុញលើកទឹកចិត្តយ៉ាងសកម្មក្នុងការអនុវត្តការការពារ សុវត្ថិភាពកុមារនៅក្នុងអង្គការរបស់យើង។

**ក.** មន្ត្រី អ្នកស្ម័គ្រចិត្ត និងយុវជនទាំងអស់ នឹងផ្តល់ជូនសេចក្តីចម្លងល័ក្ខខណ្ឌការងាររបស់កាកបាទក្រហមកម្ពុជា និងគោលនយោបាយការពារកុមារ។

**ខ.** មន្ត្រី អ្នកស្ម័គ្រចិត្ត និងយុវជនកាកបាទក្រហមទាំងអស់នឹងទទួលបានការណែនាំ អំពីគោលនយោបាយការពារកុមារ ដែលជាផ្នែកមួយនៃការណែនាំតម្រង់ទិសរបស់ពួកគេស្តីពីកាកបាទក្រហមកម្ពុជា។

**គ.**កាកបាទក្រហមកម្ពុជា នឹងផ្ញើទំនាក់ទំនងគោលនយោបាយការពារកុមារឱ្យដល់គ្រប់ផ្នែកដែលពាក់ព័ន្ធ ដែលរួមមានប្រធាន និងសមាជិកគណៈកម្មាធិការ មន្ត្រី អ្នកស្ម័គ្រចិត្ត យុវជន ទីប្រឹក្សា និងដៃគូទាំងអស់។

**ឃ.** មន្ត្រី អ្នកស្ម័គ្រចិត្ត និងយុវជន ចូលថ្មី ដែលត្រូវធ្វើការជាមួយកុមារ តម្រូវអោយគោរពតាមដំណើរការជ្រើសរើស ស្តីពីសកម្មភាពសុវត្ថិភាពកុមារ ដូចមានចែងខាងក្រោម ៖

- កំនត់សំណួរដែលត្រូវសំភាសន៍ ត្រូវបញ្ចូលក្នុងតារាងសំភាសន៍ (ដោយរួមមាន សំណួរអំពី ការផ្តន្ទាទោស និងការចោទប្រកាន់ពីអតីតកាល)។
- អ្នកធានាអះអាងជានិច្ចជាកាល នឹងត្រូវបានចោទសួរអំពីចម្ងល់ផ្សេងៗ នៃបេក្ខជន ឬការប្តឹងតវ៉ាដែលបានធ្វើឡើងអំពី បេក្ខជនរូបនោះ។

**ង.** កាកបាទក្រហមកម្ពុជា នឹងធានាថា គោលនយោបាយការពារកុមារ និងតម្រូវការផ្សេងៗ នឹងត្រូវបានបញ្ជាក់ក្នុងតារាងប្រកាសជ្រើសរើសមន្ត្រី អ្នកស្ម័គ្រចិត្ត និងយុវជនចូលថ្មី។

ច. កាកបាទក្រហមកម្ពុជា នឹងមិនអនុញ្ញាតឱ្យបុគ្គលណាមួយធ្វើការ ឬមានទំនាក់ទំនង ជាមួយកុមារ ប្រសិនបើពួកគេបង្កហានិភ័យដែល មិន អាចទទួលយកបានទៅលើសុវត្ថិភាព ឬ សុខុមាលភាពកុមារ។

ឆ. រាល់កិច្ចសន្យាការងាររបស់មន្ត្រី ដែលបំរើការនៅកាកបាទក្រហម កម្ពុជា ក្នុងវិសាលភាពគោលនយោបាយការពារកុមារ នេះដោយរួម បញ្ចូលទាំងការផ្តល់សិទ្ធិអំណាច នៃកាកបាទក្រហមកម្ពុជា និងត្រូវ បញ្ឈប់ពីការងារ ឬព្យួរការងារ ឬផ្ទេរភារកិច្ចទៅកន្លែងដទៃ ប្រសិនបើ បុគ្គលរូបនោះ បំពានលើលក្ខខ័ណ្ឌការងាររបស់កាកបាទក្រហម កម្ពុជា រួមទាំងក្រមសីលធម៌នៃការការពារកុមារ។

## ៦.៣ ការគ្រប់គ្រងបណ្តឹងតវ៉ា និងដំណើរការរៀបចំរបាយការណ៍

ក. កាកបាទក្រហមកម្ពុជា ធ្វើការពិចារណាថា ការរំលោភ និងការ កេងប្រវ័ញ្ចលើកុមារជាអំពើមិនអាចទទួលយកបានទេ ហើយកាក បាទក្រហមកម្ពុជា ប្រើនីតិក្រមច្បាស់លាស់សម្រាប់ចាត់វិធានការធ្វើ សកម្មភាព និងរបាយការណ៍។ មន្ត្រី អ្នកស្ម័គ្រចិត្ត យុវជន និង សមាជិក-សមាជិកា កាកបាទក្រហមកម្ពុជាទាំងអស់ ត្រូវរាយការណ៍ ជាបន្ទាន់នូវ៖

- ករណីសង្ស័យអំពីការរំលោភ ឬការកេងប្រវ័ញ្ចលើកុមារពី សំណាក់ អ្នកគ្រប់គ្រងផ្ទាល់ និងចម្លងជូនអាជ្ញាធរដែនដី។
- ការបើកចំហ ឬការចោទប្រកាន់ពីសំណាក់កុមារ ឬសមាជិក សហគមន៍ ឬមន្ត្រី ទាក់ទងនឹងសុវត្ថិភាព ការរំលោភ ឬការ កេងប្រវ័ញ្ចលើកុមារ។
- ការសង្កេតណាមួយ ឬការប្រព្រឹត្តណាមួយដែលសម្តែងឡើង ដោយ មន្ត្រី អ្នកស្ម័គ្រចិត្ត យុវជន ឬសមាជិក-សមាជិកា របស់

កាកបាទក្រហមកម្ពុជា ដែលបំពារបំពានលើគោលនយោបាយការពារកុមារ។

- ការប្រើប្រាស់មិនសមរម្យនៃរូបថត ឬឧបករណ៍ថតវីដេអូ ឬកុំព្យូទ័រ រួមទាំងកស្តុតាង នៃរូបភាពអាសអាភាសន៍របស់កុមារ។
- មន្ត្រី អ្នកស្ម័គ្រចិត្ត យុវជន និងសមាជិក-សមាជិកា កាកបាទក្រហមកម្ពុជា ដែលជាប់សង្ស័យលើការប្រព្រឹត្តអាចជាប់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរ។

**ខ.** របាយការណ៍អាចធ្វើឡើងដោយផ្ទាល់មាត់ និងដោយការបំពេញបែបបទតារាងហេតុការណ៍ កាកបាទក្រហមកម្ពុជា។ កំនត់ត្រានៃព័ត៌មាន ពាក្យបណ្តឹង អាចធ្វើឱ្យសម្រេចបានគោលដៅជាយុទ្ធសាស្រ្តរបស់កាកបាទក្រហមកម្ពុជា និងអនុញ្ញាតឱ្យមានការកំណត់អត្តសញ្ញាណនៃនិន្នាការណា មួយ ឬបញ្ហាប្រព័ន្ធណាមួយដែលអាចជួយធ្វើឱ្យបានប្រសើរឡើងក្នុងការផ្តល់សេវា។ ពាក្យបណ្តឹងទាំងឡាយគួរត្រូវបានកត់ត្រាទុកក្នុងតារាងហេតុការណ៍នៅគ្រប់កម្រិតទាំងអស់ នៃកាកបាទក្រហមកម្ពុជា។ ទោះជាយ៉ាង ណាក៏ដោយ ពាក្យបណ្តឹងដែលមានលក្ខណៈសម្ងាត់ និងរសើបខ្ពស់ ឬជាប់ទាក់ទងនឹងការប្រព្រឹត្តរបស់មន្ត្រី គួររក្សាទុកដាច់ដោយឡែកក្នុងប្រព័ន្ធដែលមានការឯកភាពនៃកាកបាទក្រហមកម្ពុជា។

**គ.** អ្នកដែលបានទទួលរបាយការណ៍នេះ ដោយមានការពិគ្រោះយោបល់ ជាមួយអ្នកគ្រប់គ្រងផ្ទាល់ នឹងធ្វើការពិភាក្សាគ្នាអំពីក្តីបារម្ភ និងធ្វើការសម្រេចចិត្ត លើវិធានការណ៍បន្ទាប់នេះរួមមាន៖

- ធ្វើការសំភាសន៍ជាមួយអ្នកពាក់ព័ន្ធជាក់លាក់ និងអ្នកដែលធ្វើរបាយការណ៍នេះ ឬសាក្សីផ្សេងទៀត ដើម្បីប្រមូលព័ត៌មាន

បន្ថែមទៀតដើម្បីធ្វើការសម្រេចចិត្ត ឬក៏រាយការណ៍ទៅនគរបាលមូលដ្ឋាន ឬអង្គាធរការពារកុមារ ឬភ្នាក់ងារបង្អែកដោះស្រាយក្តីបារម្ភផ្ទៃក្នុង ប្រសិន បើករណីនោះមិនមែនជាបទឧក្រិដ្ឋ។

**ឃ.** កាកបាទក្រហមកម្ពុជា ទទួលខុសត្រូវដើម្បីធានាថា មន្ត្រី ឬអ្នកស្ម័គ្រចិត្ត ដែលបានរំលោភលើក្រមប្រតិបត្តិ ត្រូវបានដកចេញពីការងារ ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយកុមារ ត្រូវផ្អាក ឬត្រូវបញ្ចប់ពីការងារប្រសិនបើចាំបាច់។ (សូមមើលល័ក្ខខ័ណ្ឌការងារកាកបាទក្រហមកម្ពុជា)ដំណើរការនេះនឹងត្រូវបានដោះស្រាយដោយក្រុមប្រឹក្សាវិន័យ កាកបាទក្រហមកម្ពុជា។

## ៦.៣.១ ការណែនាំ ការគ្រប់គ្រងពាក្យបណ្តឹងតវ៉ា និងឧប្បត្តិហេតុ

កាកបាទក្រហមកម្ពុជា ប្តេជ្ញាចិត្តជានានូវ សុវត្ថិភាព សុខមាលភាពសម្រាប់កុមារពាក់ព័ន្ធកិត្តិយស និងសិទ្ធិរបស់ពួកគេគ្រប់ពេលគ្រប់កាលៈទេសៈ៖

ក. កាកបាទក្រហមកម្ពុជា នឹងខិតខំប្រឹងប្រែងគ្រប់យ៉ាងដើម្បីការពារសិទ្ធិ និងសុវត្ថិភាពរបស់កុមារ តាមរយៈការស៊ើបអង្កេត។

ខ.កាកបាទក្រហមកម្ពុជា នឹងដោះស្រាយក្តីកង្វល់ទាំងឡាយដែលបានលើកឡើងដោយភាពហ្មត់ចត់ និងធ្វើអោយប្រកដថារាល់ភាគីទាំងឡាយទទួលបានការដោះស្រាយក្តីកង្វល់ ដោយភាពយុត្តិធម៌។

គ. កាកបាទក្រហមកម្ពុជា ធ្វើយ៉ាងណាអោយសេចក្តីរាយការណ៍នេះរក្សាការសម្ងាត់ យុត្តិធម៌ និងទាន់ពេលវេលា។

ឃ.កាកបាទក្រហមកម្ពុជា នឹងធានាថា ផលប្រយោជន៍របស់អ្នកដែលរាយការណ៍ ដោយសុទ្ធចិត្ត នឹងត្រូវបានការពារ។ សេចក្តីរាយការណ៍ទាំងឡាយដែលធ្វើឡើងដោយសុទ្ធចិត្ត នឹងត្រូវបានត្រួតពិនិត្យឡើងវិញ ក្នុង

គោលបំណង ផ្តល់ផលប្រយោជន៍ដ៏ល្អបំផុត សម្រាប់កុមារដោយមិន គិតពីលទ្ធផលនៃការស៊ើបអង្កេត។

ង.មន្ត្រីណាម្នាក់ ដែលមានចេតនាធ្វើបាយការណ៍ក្លែងបន្លំ នឹងត្រូវប្រឈមមុខ និងបទវិន័យ។

## ៦.៤ ការផ្សព្វផ្សាយ និង បណ្តុះបណ្តាល

មន្ត្រី អ្នកស្ម័គ្រចិត្ត និងសមាជិកទាំងអស់ ដែលធ្វើការដោយផ្ទាល់ជាមួយកុមារ ត្រូវចូលរួម ក្នុងការផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីការការពារកុមារ។

## ៦.៥ ការរៀបចំ និង កម្មវិធីនៃការគ្រប់គ្រងហានិភ័យ

កាកបាទក្រហមកម្ពុជា ធានាក្នុងការកំណត់ហានិភ័យទាំងឡាយ ដែលទាក់ទងនឹងការពារកុមារនៅគ្រប់កម្មវិធីទាំងអស់ និងដោយមានការពិភាក្សាជាមួយមន្ត្រី ដើម្បីអនុវត្តសកម្មភាពយុទ្ធសាស្ត្រសម្រាប់ដោះស្រាយហានិភ័យដែលនឹងកើតមានឡើង។

# ៧. ការតាមដាន និងការពិនិត្យឡើងវិញ

ការតាមដាន ការអនុវត្តគោលនយោបាយការពារកុមារ គឺជាការទទួលខុសត្រូវរបស់មន្ត្រី ជាពិសេស នាយក នាយកដ្ឋានធនធានមនុស្ស និង អគ្គលេខាធិការ។

គោលនយោបាយការពារកុមារ នឹងត្រូវពិនិត្យឡើងវិញរៀងរាល់ ៤ ឆ្នាំម្តង ឬមុនកាលកំណត់ ប្រសិនបើមានការផ្លាស់ប្តូរច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិ ដើម្បីអោយគោលនយោបាយការពារកុមារនេះ មានលក្ខណៈបច្ចុប្បន្នភាពប្រសិទ្ធភាពនិងសមស្រប។

## ឧបសម្ព័ន្ធ

### <u>ក្រមប្រតិបត្តិស្តីពីការការពារកុមារ</u>

មន្ត្រី អ្នកស្ម័គ្រចិត្ត សមាជិក-សមាជិកា កាកបាទក្រហមកម្ពុជាទាំងអស់ និងភ្ញៀវ ឬមន្ត្រីជាប់កិច្ចសន្យាជាមួយកាកបាទក្រហមកម្ពុជាទាំងអស់ត្រូវ ៖

- ធ្វើសកម្មភាព ដោយអនុលោមតាមគោលការណ៍គ្រឹះរបស់ចលនាកាកបាទក្រហម-អឌ្ឍចន្ទក្រហម។
- ផ្តល់ការគោរពដល់កុមារដោយមិនប្រកាន់ អម្បូរ ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ គំនិត ជាតិ ជនជាតិ ឬសង្គម ទ្រព្យសម្បត្តិ ពិការភាពកំណើត និងស្ថានភាពផ្សេងៗ។
- មិនត្រូវប្រើប្រាស់ពាក្យសំដី ឬអាកប្បកិរិយាណាមួយដែលមានលក្ខណៈមិនសមរម្យ ការរំខាន ការបំពារបំពាន ការបង្ខំរួមភេទ ការបញ្ចុះបញ្ចូល ឬទង្វើណាមួយ ដែលមិនសមរម្យចំពោះវប្បធម៌ប្រពៃណីជាតិយើងទៅលើកុមារ។
- មិនត្រូវដាក់បញ្ចូលកុមារក្នុងសកម្មភាពទាំងឡាយណា ដែលមានការពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទគ្រប់រូបភាពដូចជា៖ ការទិញសេវា ឬសកម្មភាពផ្លូវភេទ ចំពោះកុមារដែលមានអាយុមិនសមស្រប ឬសកម្មភាពទាំងឡាយណាដែលមិនសមស្របទាក់ទងទៅនឹងច្បាប់។
- ត្រូវធានាឱ្យបានថា ត្រូវតែមានមនុស្សពេញវ័យម្នាក់នៅធ្វើការជាមួយកុមារគ្រប់ទីកន្លែង និងពេលដែលធ្វើការជាមួយកុមារ។
- មិនត្រូវហៅកុមារឱ្យទៅផ្ទះរបស់ខ្លួន លើកលែងតែពួកគេ ស្ថិតក្នុងស្ថានភាពរងរបួស ឬគ្រោះថ្នាក់លើផ្នែករាងកាយ។

- មិនត្រូវគេងជិតស្និទ្ធជាមួយកុមារដែលគ្មានការថែរក្សា លើកលែងតែមានការចាំបាច់បំផុត។ ក្នុងករណីចាំបាច់អ្នកត្រូវតែសុំការអនុញ្ញាត ពីអ្នកគ្រប់គ្រងជាមុន និងធានាថាមានមនុស្សពេញវ័យមួយនាក់នៅជាមួយ(ប្រសិនបើមាន)។
- ប្រើប្រាស់កុំព្យូទ័រ ទូរស័ព្ទដៃ វីដេអូ ប្រព័ន្ធផ្សព្វផ្សាយ និង ម៉ាស៊ីនថតអោយបានសមរម្យ និងមិនធ្វើឱ្យមានការរំខាន ឬកេងប្រវ័ញ្ចលើកុមារ ឬទទួលបានរូបភាពអាក្រាតរបស់កុមារតាមរយៈការផ្សព្វផ្សាយ (អាចពិនិត្យមើលផងដែរនៅមាត្រាខាងក្រោមដែលចែងអំពីការប្រើប្រាស់រូបភាពរបស់កុមារសំរាប់តែការងារប៉ុណ្ណោះ)។
- មិនត្រូវដាក់ទោសផ្នែករូបរាងកាយ ឬ ក្រមសីលធម៌លើកុមារ (លើកលែងតែកូនបង្កើត)។
- មិនត្រូវជួលកុមារអោយទៅធ្វើការតាមផ្ទះ ឬការងារប្រើកំលាំងពលកម្មដទៃទៀត ឬធ្វើពលកម្មផ្សេងៗដែលមានលក្ខណៈមិនសមស្របទៅនឹងអាយុរបស់ពួកគេ ឬក្នុងដំណាក់កាលវ័យលូតលាស់របស់កុមារ ដែលធ្វើអោយខកខានដល់ការសិក្សា និងសកម្មភាពរីករាយទាំងឡាយ ឬធ្វើអោយពួកគេទទួលរងហានិភ័យខ្ពស់ ដូចជាការរងរបួស។
- ប្រតិបត្តិតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា រួមទាំងច្បាប់ពលកម្មដែលពាក់ព័ន្ធទៅនឹងពលកម្មកុមារ។
- រាយការណ៍ជាបន្ទាន់អំពីការព្រួយបារម្ភ ឬការចោទប្រកាន់អំពីការរំលោភឬការកេងប្រវ័ញ្ចលើកុមារ ឬក៏ការអនុវត្តតាមគោលនយោបាយ ដោយផ្អែកលើនីតិក្រមកាកបាទក្រហមកម្ពុជា។
- លាតត្រដាងជាបន្ទាន់នូវរាល់ការចោទប្រកាន់ ការផ្តន្ទាទោស ឬរាល់លទ្ធផលទាំងឡាយ ដែលចេញពីការប្រព្រឹត្តបទល្មើស ដែល

មានជាប់ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ ដែលកើតឡើងមុនពេល ឬកំឡុងពេលទំនាក់ទំនងជាមួយភាគបាទក្រហមកម្ពុជា។

## ការប្រើរូបភាពរបស់កុមារដើម្បីគោលបំណងការងារ

នៅពេលដែលថតរូប ឬថតភាពយន្តរបស់កុមារសម្រាប់គោលបំណងការងារ ខ្ញុំនឹង៖

- មុននឹងថតរូប ឬថតខ្សែភាពយន្តកុមារ ខ្ញុំត្រូវស្វាបស្ទង់និងព្យាយាមប្រតិបត្តិតាមប្រពៃណី ឬល័ក្ខខ័ណ្ឌក្នុងការផលិតបោះពុម្ពផ្សាយរូបភាពបុគ្គល។
- មុននឹងថតរូប ឬថតភាពយន្តកុមារ ត្រូវមានការយល់ព្រមពីកុមារ ឬឪពុកម្តាយ ឬអាណាព្យាបាលកុមារ។ ក្នុងនោះខ្ញុំត្រូវតែពន្យល់ថារូបភាពនេះនឹងយកទៅប្រើនៅកន្លែងណា និងប្រើក្នុងល័ក្ខខ័ណ្ឌបែបណា។
- ធ្វើអោយប្រាកដថារូបភាព ខ្សែភាពយន្ត វីដេអូ និង ឌីវីឌី ត្រូវបង្ហាញរូបភាពអំពីកុមារ ដោយរក្សាកិត្តិយស និងការគោរពដល់ពួកគេហើយនឹងមិនបង្កលក្ខណៈងាយរងគ្រោះ ឬការបង្អាប់បញ្ញា។ កុមារគួរមានសម្លៀកបំពាក់សមរម្យ និងមិនត្រូវបានថតក្នុងរូបភាពទាក់ទងនឹងផ្លូវភេទឡើយ។
- ធ្វើអោយប្រាកដថារូបភាពត្រូវបង្ហាញ ពីការពិតដោយភាពស្មោះត្រង់
- ធ្វើអោយប្រាកដថារូបភាព ឬចំណងជើងឯកសារមិនបង្ហាញពីព័ត៌មានអត្តសញ្ញាណរបស់កុមារ។

ខ្ញុំយល់ថាការទទួលខុសត្រូវគឺជាបន្ទុករបស់ខ្ញុំក្នុងនាមជា មន្ត្រី អ្នកស្ម័គ្រចិត្ត របស់កាកបាទក្រហមកម្ពុជា ក្នុងការប្រើសុភវិនិច្ឆ័យ និងការជៀសវាងរាល់សកម្មភាព ឬការប្រព្រឹត្តិទាំងឡាយណាដែលអាចត្រូវចាត់ទុកថាជាការរំលោភលើកុមារ ខណៈពេលកំពុងអនុវត្តសកម្មភាពរបស់កាកបាទក្រហមកម្ពុជា។

ហត្ថលេខា______________________________